| MELON ROUGE AGENCY | GIZ<br>QUOTATION<br>Size: 85 x 60cm<br>22 - Jun - 2022 | MATERIALS | COLORS<br>CMYK | APPROVAL<br>THE SIGNATURE OF THE PRESENT DOCUMENT BY THE CLIENT VALIDS THE DOCUMENT FOR PRINTING AND CANNOT BE CHANGED AFTERWARDS : |
|---|---|---|---|---|

ក្រសួងផែនការ

# លោកស្រីប៊ុន សេង

**អាយុ៦៨ឆ្នាំ (ស្រ្តីវ័យចំណាស់ជាមេគ្រួសារ)**
**នៅភូមិព្រៃកអង្គុយ ឃុំសៀមរាប ស្រុកកណ្តាលស្ទឹង ខេត្តកណ្តាល**

នៅពេលប្តីខ្ញុំនៅរស់ គាត់គឺជាគ្រូបង្រៀន ហើយនៅពេលពួកយើងរស់នៅជាមួយគ្នាអ្វីៗគ្រប់យ៉ាងហាក់ដូចជាមិនមានការលំបាកទេ។ បន្ទាប់ពីគាត់បានស្លាប់ទៅ ខ្ញុំនៅតែម្នាក់ឯង ហើយនៅពេលនោះហើយដែលអ្វីៗគ្រប់យ៉ាងបានចាប់ផ្តើមលំបាក។ ខ្ញុំបានសម្រេចចិត្តចុះឈ្មោះស្នើសុំបណ្ណសមធម៌ ដោយសារពេលនោះខ្ញុំក្រីក្រខ្លាំងពេក ហើយក៏ពិបាកក្នុងការរកប្រាក់ចំណូលផងដែរ។ ដោយសារមានការរីករាលដាលនៃជំងឺកូវីដ ១៩ ខ្ញុំមិនអាចរកប្រាក់ចំណូលបានទេ ហេតុនេះប្រាក់ចំណូលសំខាន់សម្រាប់គ្រួសារខ្ញុំមានតែមួយគត់ គឺជាប្រាក់ឧបត្ថម្ភរបស់រាជរដ្ឋាភិបាលដែលផ្តល់ជូនគ្រួសារក្រីក្រ និងងាយរងគ្រោះ។ ប្រាក់ឧបត្ថម្ភនេះអាចឱ្យខ្ញុំទិញអង្ករបានមួយបាវសម្រាប់គ្រួសារខ្ញុំ។ ខ្ញុំក៏បានដឹងដែរថា គ្រួសារដែលមានបណ្ណសមធម៌ ដូចជាខ្ញុំអ៊ីចឹង នៅពេលមានជំងឺ ខ្ញុំអាចទៅជួបគ្រូពេទ្យ ដើម្បីព្យាបាលជំងឺដោយឥតគិតថ្លៃ។



Australian Aid
កិច្ចសហប្រតិបត្តិការអាល្លឺម៉ង់ DEUTSCHE ZUSAMMENARBEIT
អនុវត្តដោយ៖ giz Deutsche Gesellschaft für Internationale Zusammenarbeit (GIZ) GmbH
UNDP

ក្រសួងផែនការ

# លោកស្រី ឡាយ កុសល

**អាយុ៣៥ឆ្នាំ (ស្ត្រីធ្លាប់មានផ្ទៃពោះ និងទទួលប្រាក់ឧបត្ថម្ភ)**
**នៅភូមិព្រៃកអង្គុយ ឃុំសៀមរាប ស្រុកកណ្តាលស្ទឹង ខេត្តកណ្តាល**

ដោយសារគ្រួសារខ្ញុំនៅតែក្រីក្រ គ្រួសារខ្ញុំបានទទួលបណ្ណសមធម៌។ ចាប់តាំងពីយើងមានបណ្ណសមធម៌មក គ្រួសារយើងមានជីវភាពប្រសើរជាងមុន។ យើងបានទទួលការជួយឧតបត្ថម្ភជាបន្តបន្ទាប់ ប៉ុន្តែជាពិសេស ប្រសិនបើខ្ញុំពុំមានបណ្ណសមធម៌ទេ ខ្ញុំត្រូវចំណាយលុយរាល់ពេលដែលខ្ញុំទៅជួបជាមួយគ្រូពេទ្យជាមួយកូនរបស់ខ្ញុំ។ បណ្ណសមធម៌ធ្វើឱ្យយើងមានសុវត្ថិភាព។ ពួកយើងក៏ទទួលបានការគាំទ្រផ្សេងៗផងដែរ តាមរយៈការប្រើប្រាស់បណ្ណសមធម៌នេះ។ ក្រៅពីទទួលបានប្រាក់ឧបត្ថម្ភរបស់រាជរដ្ឋាភិបាលនៅអំឡុងពេលនៃការរីករាលដាលនៃជំងឺកូវីដ ១៩ ខ្ញុំក៏ទទួលបានថវិកាពីកម្មវិធីឧបត្ថម្ភសាច់ប្រាក់ចំពោះស្ត្រីមានផ្ទៃពោះ និងកុមារអាយុក្រោម២ឆ្នាំថែមទៀត ដោយទទួលបានថវិកាចំនួន ៤ម៉ឺនរៀលរៀងរាល់ខែ ចាប់ពីខ្ញុំមានផ្ទៃពោះ៦ខែ រហូតដល់កូនខ្ញុំអាយុ២ឆ្នាំ។ ខ្ញុំបានឆ្លងទន្លេនៅមន្ទីរពេទ្យជ័យជំនះរបស់រដ្ឋ និងបានប្រើប្រាស់បណ្ណសមធម៌របស់ខ្ញុំ ដោយត្រឹមតែមិនអស់លុយទេ ថែមទាំងបានលុយមកវិញទៀត។ អ៊ីចឹងខ្ញុំពុំចាំបាច់ចំណាយប្រាក់លើថ្លៃសម្រាល និងថ្នាំពេទ្យឡើយ។



Australian Aid

កិច្ចសហប្រតិបត្តិការអាល្លឺម៉ង់
DEUTSCHE ZUSAMMENARBEIT

អនុវត្តដោយ៖
giz Deutsche Gesellschaft für Internationale Zusammenarbeit (GIZ) GmbH

UNDP

ក្រសួងផែនការ

# លោក អៀង យុន

**អាយុ ៦៦ឆ្នាំ ជាសមាជិក ក្រុមប្រឹក្សាឃុំ សៀមរាប ស្រុកកណ្ដាលស្ទឹង ខេត្តកណ្ដាល**



ខ្ញុំបានធ្វើការងារអត្តសញ្ញាណកម្មគ្រួសារក្រីក្រតាំងពីឆ្នាំ២០១១។ យើងបានចាប់ផ្ដើមអនុវត្តដំណើរការកំណត់អត្តសញ្ញាណគ្រួសារក្រីក្រតាមការស្នើសុំដំបូងនៅឆ្នាំ២០២១។ ការប្រើប្រាស់នីតិវិធីអត្តសញ្ញាណកម្មគ្រួសារក្រីក្រតាមការស្នើសុំធ្វើឱ្យគ្រួសារក្រីក្របានទទួលបណ្ណសមធម៌ឆាប់រហ័សជាងមុន ដែលជាហេតុធ្វើឱ្យពួកគាត់ទទួលបានផលប្រយោជន៍ផ្សេងៗពីបណ្ណនេះរហ័សជាងមុនផងដែរ។ ខ្ញុំជឿជាក់ថា បណ្ណសមធម៌មានសារសំខាន់ណាស់ ព្រោះវាផ្ដល់នូវផលប្រយោជន៍ជាច្រើន។ វាបានជួយដល់គ្រួសារក្រីក្រនៅក្នុងឃុំឱ្យមានជីវភាពកាន់តែសមរម្យ។ បណ្ណសមធម៌ផ្ដល់ផលប្រយោជន៍ជាច្រើនដូចជា ការទទួលបានសេវាសុខាភិបាលដោយឥតគិតថ្លៃ ការទទួលបានអាហារ-រូបករណ៍សម្រាប់សិស្សនៅបឋមសិក្សា និងអនុវិទ្យាល័យ ការបណ្ដុះបណ្ដាលវិជ្ជាជីវៈ និងការឧបត្ថម្ភជាសាច់ប្រាក់ផ្សេងៗ។ ជាក់ស្ដែង គ្រួសារក្រីក្របានទទួលជំនួយជាការឧបត្ថម្ភប្រាក់នៅអំឡុងពេលរីករាលដាលនៃជំងឺកូវីដ ១៩ ដើម្បីដោះស្រាយជីវភាពរបស់គាត់បានមួយកម្រិតទៀត។

Australian Aid

កិច្ចសហប្រតិបត្តិការ អាល្លឺម៉ង់ DEUTSCHE ZUSAMMENARBEIT

អនុវត្តដោយ៖ giz Deutsche Gesellschaft für Internationale Zusammenarbeit (GIZ) GmbH

UNDP

ក្រសួងផែនការ

# ឯកឧត្តម កែវ អ៊ូលី

**ប្រធាននាយកដ្ឋានអត្តសញ្ញាណកម្មគ្រួសារក្រីក្រនៃអគ្គនាយកដ្ឋានផែនការ ក្រសួងផែនការ**

ក្រសួងផែនការជាសេនាធិការឱ្យរាជរដ្ឋាភិបាលក្នុងការគ្រប់គ្រងដំណើរការអនុវត្តនីតិវិធីអត្តសញ្ញាណកម្មគ្រួសារក្រីក្រ ដើម្បីផ្តល់ទិន្នន័យគ្រួសារក្រីក្រជូនដល់ស្ថាប័នពាក់ព័ន្ធសម្រាប់ផ្តល់កិច្ចអន្តរាគមន៍ជំនួយសង្គមនានា សំដៅលើកកម្ពស់ជីវភាពរស់នៅ និងកាត់បន្ថយភាពក្រីក្ររបស់ប្រជាពលរដ្ឋ។ ជាក់ស្តែងនៅក្នុងបរិបទដែលប្រទេសកម្ពុជាយើងប្រឈមនឹងការរាតត្បាតនៃជំងឺកូវីដ១៩ ក្រសួងផែនការបានសហការជាមួយក្រសួងស្ថាប័នពាក់ព័ន្ធ និងដៃគូអភិវឌ្ឍន៍នានាក្នុងការរៀបចំនីតិវិធីអត្តសញ្ញាណកម្មគ្រួសារក្រីក្រតាមការស្នើ ដើម្បីកំណត់អត្តសញ្ញាណគ្រួសារក្រីក្រដែលរងផលប៉ះពាល់ដោយសារជំងឺកូវីដ ១៩ ដើម្បីឱ្យពួកគាត់ទទួលបានការគាំទ្រពីរាជរដ្ឋាភិបាល តាមរយៈកម្មវិធីឧបត្ថម្ភសាច់ប្រាក់ជូនគ្រួសារក្រីក្រ និងងាយរងគ្រោះ ព្រមទាំងទទួលបានការគាំទ្រកិច្ចគាំពារសង្គមនានា។ ចាប់ពីឆ្នាំ២០២២នេះតទៅ រាជរដ្ឋាភិបាលនឹងដាក់ឱ្យអនុវត្តនូវនីតិវិធីអត្តសញ្ញាណកម្មគ្រួសារក្រីក្រ ដោយប្រើប្រាស់ប្រព័ន្ធឌីជីថល ដើម្បីពន្លឿនដល់ដំណើរការប្រមូល និងផ្តល់ទិន្នន័យគ្រួសារក្រីក្រជូនរាជរដ្ឋាភិបាលបន្តឆ្លើយតបបន្ទាន់ដល់កិច្ចអន្តរាគមន៍ជំនួយសង្គមនានាដល់គ្រួសារក្រីក្រ និងជនងាយរងគ្រោះក្នុងប្រទេសកម្ពុជា។ ចំពោះគ្រួសារដែលគិតថាខ្លួនស្ថិតក្នុងភាពក្រីក្រ ហើយត្រូវការបណ្ណសមធម៌ សូមដាក់ពាក្យស្នើសុំសម្ភាសន៍ ដោយផ្ទាល់មាត់ ឬបំពេញពាក្យស្នើសុំទៅក្រុមការងារឃុំ សង្កាត់ ឬប្រើទម្រង់អេឡិចត្រូនិក/ឌីជីថលដែលអាចរកបាននៅលើ Public IDPoor App ឬគេហទំព័រអត្តសញ្ញាណកម្មគ្រួសារក្រីក្រ https://idpoor.gov.kh។



Australian Aid

កិច្ចសហប្រតិបត្តិការអាល្លឺម៉ង់
DEUTSCHE ZUSAMMENARBEIT

អនុវត្តដោយ៖
giz Deutsche Gesellschaft für Internationale Zusammenarbeit (GIZ) GmbH

UNDP

ក្រសួងផែនការ

# ឯកឧត្តម ឈួរ សុបញ្ញា

**ប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជាអគ្គនាយក នៃមូលនិធិជាតិ ជំនួយសង្គម ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា**



ចំពោះការអនុវត្តកម្មវិធីអត្តសញ្ញាណកម្មគ្រួសារក្រីក្រមានភាពល្អប្រសើរ និងឆ្លើយតបទាន់ពេលវេលាសម្រាប់ការអនុវត្ត។ ជាពិសេស យើងបានប្រើប្រាស់ទិន្នន័យគ្រួសារក្រីក្រនោះប្រកបដោយប្រសិទ្ធភាព និងចំគោលដៅដែលយើងចង់អនុវត្ត។

ការទទួលបានទិន្នន័យនេះ ជាក្របខណ្ឌនៃការអនុវត្តរៀងរាល់ថ្ងៃទី១០ នៃខែនីមួយៗ ក្រសួងសង្គមកិច្ចទាញយកទិន្នន័យគ្រួសារក្រីក្រតាមរយៈប្រព័ន្ធ API ដែលភ្ជាប់មកពីប្រព័ន្ធទិន្នន័យរបស់ក្រសួងផែនការចូលមកប្រព័ន្ធទិន្នន័យរបស់ក្រសួងសង្គមកិច្ច។ បន្ទាប់មក យើងធ្វើការដកចេញនូវទិន្នន័យដែលត្រួតស៊ីគ្នានៅក្នុងខែនីមួយៗ។

តាមរយៈទិន្នន័យនេះ យើងបានប្រើប្រាស់ទិន្នន័យនេះសម្រាប់ ១) ផ្តល់សាច់ប្រាក់ដល់គ្រួសារក្រីក្រដែលរងផលប៉ះពាល់ដោយសារជំងឺកូវីដ ១៩ ២) ផ្តល់សាច់ប្រាក់ដល់ស្ត្រីមានផ្ទៃពោះ និងកុមារអាយុក្រោម២ឆ្នាំ ហើយយើងបានប្រើប្រាស់ទិន្នន័យនេះសម្រាប់ស្វែងរកអត្តសញ្ញាណគ្រួសារក្រីក្រដែលជាក្រុមគោលដៅផ្សេងទៀតដែរដូចជា កុមារ ស្ត្រីមានផ្ទៃពោះ មនុស្សចាស់ និងជនមានពិការភាពក្រីក្រផងដែរ។

Australian Aid

កិច្ចសហប្រតិបត្តិការអាល្លឺម៉ង់
DEUTSCHE ZUSAMMENARBEIT

អនុវត្តដោយ៖
giz Deutsche Gesellschaft für Internationale Zusammenarbeit (GIZ) GmbH

UNDP